# គម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣

## ករណីសិក្សា

| | |
|---|---|
| **ស៊ី.ស៊ី.ចេប/ផ្នែក៖**<br>*ទប់ស្កាត់បទល្មើស និងសុវត្ថិភាពសហគមន៍*<br>**បុគ្គលបំពេញទំរង់បែបបទ៖**<br>*ឈ្មោះ ៖ វ៉ែនសុភ័ណ*<br>*តួនាទី ៖ មន្ត្រីសំរបសំរួលថ្នាក់ស្រុកនៃ*<br>*គណៈកម្មាធិការប្រត្រិបត្តិខេត្តកំពង់ធំ* | **កាលបរិច្ឆេទ៖** *ខែមេសា ឆ្នាំ២០១១*<br>**អ្នកដែលត្រូវបានសម្ភាសន៍៖**<br>*ឈ្មោះ ៖ គឹមសុកែន អាយុ៖ ២៥ ឆ្នាំ ភេទ៖ ប្រុស*<br>*ភូមិ៖ ជីមាស ឃុំ៖ ម្សាក្រង ស្រុក៖ ស្ទោង*<br>*ខេត្ត៖ កំពង់ធំ* |

### ទិសដៅ

*យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រ៤នៃកម្មវិធីទប់ស្កាត់បទល្មើស និងសុវត្ថិភាពសហគមន៍ (ទ.ប.ស.ស )គឺការលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ និងជំរុញឲ្យមាន ឥរិយាបថល្អៗ សម្រាប់សង្គមតាមរយៈការផ្តល់សេវាផ្នែកសង្គម ផ្នែកសេដ្ឋកិច្ច និងអប់រំ ដោយផ្តោតជាពិសេសទៅ លើក្រុមអនីតិជន និងយុវជនដែលមានឥរិយាបថអាចពាក់ព័ន្ធទៅនឹងបទល្មើស ឬរងគ្រោះ ដោយសារបទល្មើស។ ករណីសិក្សាខាងក្រោមនេះ គឺជាឧទាហរណ៍មួយនៃការគាំទ្រ របស់គម្រោង ស៊ី.ស៊ី.ចេប ដែលបានចូលរួមចំណែកធ្វើអោយសហគម៌មានភាពរុងរឿងប្រកបដោយបរិស្ថានសុវត្ថិភាពនិងសន្តិសុខល្អ។*

### ដំណើររឿង



*ប្អូន **គឹម សុកែន** មានអាយុ២៥ឆ្នាំគឺជាសមាជិកទី៨ ក្នុងចំណោមសមាជិកទាំង១០នាក់ ដែលមានម្តាយជាស្ត្រីមេម៉ាយ។*

***គឹម សុកែន** បានបោះបង់ចោលការសិក្សានៅថ្នាក់ទី៦ ក្នុងឆ្នាំ២០០៤។ ផ្ទុយទៅវិញគាត់បានសេពគប់ជាមួយនឹងក្មេងទំនើង និងក្រុមផឹកស៊ីបង្ករទំនាស់ដែលធ្វើឲ្យប្រជាពលរដ្ឋតែងតែមានការព្រួយបារម្ភអំពីសន្តិសុខក្នុងសហគមន៍។ អាជ្ញាធរមូលដ្ឋានបានធ្វើការសាកសួរនិងអប់រំណែនាំដល់*

គាត់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តខុសឆ្គងរបស់គាត់នៅក្នុងសហគមន៍មូលដ្ឋានចំនួនជាច្រើនលើករួចមកហើយ។

**ការជួយអន្តរាគមន៍**

ក្នុងឆ្នាំ២០១០ កម្មវិធីរបស់គម្រោង ស៊ីស៊ីចេប៣ ប្រចាំខេត្តកំពង់ធំ បានបង្កើតអោយមានកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកាត់សក់ដល់ក្រុមគោលដៅដែលបានទទួលការអប់រំច្បាប់កន្លងមកដើម្បីបង្កអោយពួកគាត់យកទៅប្រកបមុខរបរចិញ្ចឹមគ្រួសារ។

បន្ទាប់ពីវគ្គអប់រំផ្សព្វផ្សាយច្បាប់ ក្រុមការងារបានជួបជាមួយ ***សុកែន*** ដើម្បីផ្តល់ព័ត៌មាន និងពន្យល់គាត់អំពីគម្រោងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈខ្នាតតូច និងសាកសួរគាត់ថាតើគាត់មានបំណងចូលរួមក្នុងគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈដែរឬទេ។ ក្រោយពីបានយល់ព្រមចូលរួមជាមួយគម្រោងនេះ ***សុកែន*** ក៏ត្រូវបានជ្រើសរើសជាបេក្ខជន១រូបក្នុងចំណោមបេក្ខជនគោលដៅទាំង១០រូប។



***សុកែន*** បានទទួលវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកាត់សក់ដែលមានរយៈពេល៥ខែ។ បន្ទាប់ពីបានបញ្ចប់វគ្គនេះ គាត់ទទួលបានសំភារៈ និងបរិក្ខារកាត់សក់១សម្រាប់ពីគម្រោង ហើយបានបើកតូបកាត់សក់ផ្ទាល់ខ្លួនក្នុងផ្សារនៃភូមិជីមាស ដែលគាត់រស់នៅសព្វថ្ងៃ។

**ការផ្លាស់ប្តូរឥរិយាបថ**

ចាប់តាំងពីខែវិច្ឆិកាឆ្នាំ២០១០ ***សុកែន*** មិនបានប្រឡូកជីវិតជាមួយក្រុមក្មេងទំនើង និងក្រុមផឹកស៊ីបង្ករជម្លោះទៀតឡើយ។ ពេលនេះគាត់មានការមមារញឹកជាមួយនឹងតូបកាត់សក់របស់គាត់ ហើយដោយសារជំនាញថ្មីនេះ គាត់អាចរកប្រាក់ចំណូលបានរាល់ថ្ងៃដើម្បីជួយគ្រួសារគាត់។

លោកប្រធានភូមិបានបញ្ជាក់ថា ពេលនេះសហគមន៍មិនមានការភ័យខ្លាចអំពីការប្រព្រឹត្តិរបស់ ***សុកែន*** ទៀតទេ ហើយគេនិយាយថា ឥឡូវនេះគាត់ក្លាយជាមនុស្សថ្មីមួយរូបហើយ។

*លោកអនុសេនីយត្រីយ៍ **ស ប៉ាក់** ដែលជាមន្ត្រីនគរបាលប៉ុស្តិ៍ឃុំម្សាក្រង់បាននិយាយថា គាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារ **សុកែន** បានក្លាយទៅជាមនុស្សថ្មីម្នាក់ក្រោយពីបានចូលរួមក្នុងវគ្គអប់រំផ្សព្វផ្សាយច្បាប់និងជំនាញវិជ្ជាជីវៈកន្លងមក។*

***សុកែន*** *គឺជាគំរូមួយនៃសមាជិកសហគមន៍យុវជនដែលបានផ្លាស់ប្តូរជីវិតរបស់គាត់ពីក្រុមទំនើង និងផឹកស៊ីបង្ករជម្លោះទៅជាសមាជិកគំរូរបស់សហគមន៍សម្រាប់យុវជនដ៏ទៃទៀត។ ការផ្លាស់ប្តូរឥរិយាបថនេះបង្ហាញឲ្យឃើញថា កម្មវិធី **ទ.ប.ស.ស** ដែលទទួលបានថវិកាពីគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាបានផ្តល់ផលជាវិជ្ជមានក្នុងការកាត់បន្ថយឥរិយាបថប្រព្រឹត្តខុសឆ្គងពាក់ព័ន្ធទៅនឹងបញ្ហាបទល្មើសនានា៕*

